# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## រវាង
## រោងចក្រ ផាយឡឹតនីតស្ព័តវែរ (ខេមបូឌា) ខូអិលធីឌី
## និង
## តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ
## រោងចក្រ ផាយឡឹតនីតស្ព័តវែរ (ខេមបូឌា) ខូអិលធីឌី

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ០៨.០០ នាទីព្រឹក នៅក្នុងរោងចក្រ**ផាយឡឹតនីតស្ព័តវែរ (ខេមបូឌា) ខូអិលធីឌី** មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្វះសម្ភារវត្ថុធាតុដើម លុបចោលការបញ្ជាទិញពីភ្ញៀវ (Buyer) និង គ្មានការបញ្ជាទិញបន្តពីអ្នកបញ្ជាទិញ សម្រាប់សង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតទាំងអស់រយៈពេលចំនួន ២ខែ គឺចាប់ពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួលចំនួន ៣០ ដុល្លារអាមេរិក និង ៤០ ដុល្លារដុល្លារអាមេរិកពីរាជរដ្ឋាភិបាល ក្នុង១ខែ សម្រាប់កម្មករនិយោជិតម្នាក់ៗ។

អង្គប្រជុំបានចប់វេលាម៉ោង ០៩.៣០ នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និទ្ធស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

ថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំជូត ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០

**តំណាងកម្មករ និង តំណាងសហជីព** | **នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ផាយឡុត និត ស្ពត វែរ (ខេមបូឌា)
PILOT KNIT SPORT WEAR (CAMBODIA) CO., LTD
KINGDOM OFCAMBODIA

Kriswan Viratchkasem

ខាត់ ម៉ុងហ្គត     សំ ស៊ីន្ថន     ទូច ធារី

ឈួន សារ៉ាត់     ស៊ុន មករា     ម៉ែន ឡូ     ផែង បូរី